របាយការណ៍ព័ត៌មានស្តីអំពីថ្នាំបង្ការ

# ថ្នាំបង្ការជំងឺរលាកខួរក្បាលជប៉ុន

## *អ្វីដែលអ្នកត្រូវការដឹង*

របាយការណ៍ព័ត៌មានស្តីអំពីថ្នាំបង្ការជាច្រើនមានជាភាសាអេស្ប៉ាញនិងភាសាដទៃទៀត។ សូមមើលនៅក្នុងគេហទំព័រ www.immunize.org/vis

## 1 ហេតុអ្វីបានត្រូវទទួលថ្នាំបង្ការ

ជំងឺរលាកខួរក្បាលជប៉ុន (អក្សរកាត់ជាភាសាអង់គ្លេស JE)គឺជាការបង្ករោគបង្កដោយវីរុសជំងឺរលាកខួរក្បាលជប៉ុន។



- វាកើតឡើងយ៉ាងខ្លាំងនៅផ្នែកដាច់ស្រយាលនៃទ្វីបអាស៊ី។
- វាត្រូវចំលងតាមរយៈការខាំនៃមូសដែលមានផ្ទុកមេរោគ។ វាមិនចំលងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ឡើយ។
- គ្រោះថ្នាក់គឺមានកំរិតទាបខ្លាំងសំរាប់អ្នកធ្វើដំណើរសឹងគ្រប់រូប។ វាមានកំរិតខ្ពស់ជាងសំរាប់មនុស្សដែលរស់នៅក្នុងតំបន់ដែលជំងឺឃើញមានច្រើនជាញឹកញាប់ ឬសំរាប់អ្នកដែលធ្វើដំណើរទៅកាន់ទីនោះអស់រយៈពេលយ៉ាងយូរ។
- មនុស្សសឹងគ្រប់រូបដែលមានការបង្ករោគដោយវីរុសជំងឺ JE មិនមានរោគសញ្ញាអ្វីមួយឡើយ។ អ្នកដទៃទៀតអាចនឹងមានរោគសញ្ញាស្រាលត្រឹមតែគ្រុនក្តៅនិងឈឺក្បាលប៉ុណ្ណោះឬក៏ធ្ងន់ធ្ងរដូចការរលាកខួរក្បាល (ការបង្ករោគនៅខួរក្បាល)។
- អ្នកដែលមានជំងឺរលាកខួរក្បាលជប៉ុនអាចពើបប្រទះនឹងគ្រុនក្តៅ រឹងកញ្ចឹងក ប្រកាច់ និងសន្លប់។ ប្រហែល 1 នាក់ក្នុងចំណោម 4 នាក់ដែលមានជំងឺរលាកខួរក្បាលជប៉ុនស្លាប់បាត់បង់ជីវិត។ រហូតដល់ពាក់កណ្តាលនៃអ្នកទាំងឡាយដែលមិនស្លាប់មានពិការភាពជាអចិន្ត្រៃយ៍។
- គេជឿថាការបង្ករោគចំពោះស្ត្រីមានគិតអាចបង្កទុកទោសដល់ទារកមិនទាន់កើតរបស់គេបាន។

ថ្នាំបង្ការជំងឺ JE អាចជួយការពារអ្នកដំណើរពីជំងឺ JE បាន។

## 2 ថ្នាំបង្ការជំងឺរលាកខួរក្បាលជប៉ុន

ថ្នាំបង្ការជំងឺរលាកខួរក្បាលជប៉ុនត្រូវបានអនុម័តិយល់ព្រមឲ្យប្រើប្រាស់សំរាប់មនុស្សអាយុ 2 ខែនិងច្រើនជាងនេះ។ វាត្រូវបានគេណែនាំជាអនុសាសន៍សំរាប់អ្នកដំណើរទៅកាន់ទ្វីបអាស៊ីដែលៈ

- មានគំរោងចំណាយពេលយ៉ាងហោចណាស់មួយខែនៅក្នុងតំបន់ដែលមានជំងឺរលាកខួរក្បាលជប៉ុន
- មានគំរោងធ្វើដំណើរក្នុងរយៈពេលតិចជាងមួយខែ ប៉ុន្តែនឹងទៅទស្សនកិច្ចតំបន់ដែលនៅតំបន់ដាច់ស្រយាលនិងចំណាយពេលច្រើននៅខាងក្រៅផ្ទះ
- ធ្វើដំណើរទៅកាន់តំបន់ដែលមានការផ្ទុះឡើងនៃជំងឺ JE ឬ
- មានភាពមិនច្បាស់លាស់ពីគំរោងការធ្វើដំណើររបស់ខ្លួនពួកគេ។

បុគ្គលិកបំរើការនៅមន្ទីរពិសោធន៍ដែលស្ថិតនៅប្រឈមនឹងហានិភ័យនៃការរងប៉ះពាល់នឹងវីរុស JE គួរតែត្រូវបានចាក់ថ្នាំបង្ការផងដែរ។

ថ្នាំបង្ការនេះត្រូវបានផ្តល់ជូនបន្តបន្ទាប់គ្នាចំនួនពីរដង ដោយកំរិតប្រើប្រាស់នីមួយៗឃ្លាតពីគ្នាចំនួន 28 ថ្ងៃ។ កំរិតថ្នាំបង្ការទីពីរគួរតែផ្តល់ជូនយ៉ាងហោចណាស់មួយសប្តាហ៍មុនពេលធ្វើដំណើរ។ កុមារអាយុ ក្មេងជាង 3 ឆ្នាំទទួលកំរិតថ្នាំបង្ការតូចជាងអ្នកជំងឺដែលមានអាយុ 3 ឆ្នាំឬច្រើនជាងនេះ។

កំរិតថ្នាំបង្ការសំរាប់រំលឹកអាចនឹងត្រូវបានគេណែនាំឲ្យជាអនុសាសន៍សំរាប់គ្រប់គ្នាអាយុ 17 ឆ្នាំឬលើសពីនេះដែលត្រូវបានផ្តល់ថ្នាំបង្ការលើសពីមួយឆ្នាំកន្លងផុតទៅហើយ នៅតែស្ថិតនៅប្រឈមនឹង ហានិភ័យទទួលរងប៉ះពាល់ត្រូវនឹងវីរុស។ នៅមិនទាន់មានព័តមាននៅឡើយអំពីភាពចាំបាច់នៃកំរិតថ្នាំបង្ការសំរាប់រំលឹកសំរាប់កុមារ។

កំណត់សំគាល់ៈ *វិធីប្រសើរបំផុតក្នុងការបង្ការជំងឺ JE គឺចៀសវាងសត្វមូសខាំ។ វេជ្ជបណ្ឌិតអ្នកអាច ជូនឱវាទដល់អ្នកបាន។*

## 3 មនុស្សខ្លះមិនគួរទទួលថ្នាំបង្ការនេះទេ

- គ្រប់គ្នាដែលមានប្រតិកម្មអាលែកហ្ស៊ីធ្ងន់ធ្ងរ (គំរាមកំហែងជីវិត) ទៅនឹងកំរិតជាតិថ្នាំបង្ការ JE ចំនួនមួយកំរិតមិនគួរទទួលកំរិតថ្នាំបង្ការមួយលើកទៀតឡើយ។
- គ្រប់គ្នាដែលមានប្រតិកម្មអាលែកហ្ស៊ីធ្ងន់ធ្ងរ (គំរាមកំហែងជីវិត) ទៅនឹងសមាសធាតុផ្សំណាមួយ នៃថ្នាំបង្ការ JE មិនគួរទទួលថ្នាំបង្ការឡើយ។

*សូមប្រាប់វេជ្ជបណ្ឌិតអ្នកប្រសិនបើអ្នកមានប្រតិកម្មអាលែកហ្ស៊ីធ្ងន់ធ្ងរដែលអ្នកបានដឹង។*

- ស្ត្រីមានគិតតាមធម្មតាមិនគួរទទួលថ្នាំបង្ការ JE ឡើយ។ ប្រសិនបើអ្នកមានគិត, សូមបញ្ជាក់ ជាមួយវេជ្ជបណ្ឌិតអ្នក។

ប្រសិនបើអ្នកនឹងធ្វើដំណើររយៈពេលតិចជាង 30 ថ្ងៃ ជាពិសេសប្រសិនបើអ្នកនឹងស្នាក់នៅតំបន់ក្នុងទីប្រជុំជន សូមប្រាប់វេជ្ជបណ្ឌិតអ្នក។ អ្នកអាចនឹងមិនត្រូវការថ្នាំបង្ការឡើយ។



U.S. Department of Health and Human Services
Centers for Disease Control and Prevention

## 4 ហានិភ័យនៃប្រតិកម្មនឹងថ្នាំបង្ការ

ជាមួយនឹងថ្នាំបង្ការ ដូចទៅនឹងឱសថគ្រប់មុខទូទៅដែរ មានឱកាសដែលមានឥទ្ធិពលមិនល្អបន្ទាប់បន្សំ។ នៅពេលឥទ្ធិពលមិនល្អបន្ទាប់បន្សំលេចឡើង ពួកវាតាមធម្មតាមានកំរិតស្រាលហើយបាត់ទៅ វិញដោយខ្លួនវា។

**បញ្ហាកំរិតស្រាល**

- ការឈឺចាប់, ការឈឺចាប់, ឡើងក្រហម ឬ ហើមនៅត្រង់ចំណុចដែលថ្នាំបង្ការត្រូវបានចាក់ (ប្រ ហែលមនុស្ស 1 នាក់ក្នុងចំណោម 4 នាក់)
- គ្រុនក្តៅ (ជួបប្រទះខ្លាំងលើកុមារ) ឈឺក្បាល ឈឺសាច់ដុំ (ជួបប្រទះខ្លាំងនៅលើមនុស្សពេញវ័យ)

**បញ្ហាកំរិតមធ្យមឬកំរិតធ្ងន់ធ្ងរ**

- ការសិក្សាបានបង្ហាញថាប្រតិកម្មធ្ងន់ធ្ងរទៅនឹងថ្នាំបង្ការ JE គឺកំរកើតមានណាស់។

**បញ្ហាដែលអាចកើតឡើងបន្ទាប់ពីទទួលថ្នាំបង្ការគ្រប់មុខ**

- ការងងឹតមុខមួយភ្លែតអាចកើតឡើងបន្ទាប់ពីទំរង់ការវេជ្ជសាស្ត្រគ្រប់មុខ រួមមានការផ្តល់ថ្នាំ បង្ការ។ ការអង្គុយឬដេកទំរេតរយៈពេលប្រហែល 15 នាទីអាចជួយបង្ការការងងឹតមុខនិងរបួស បណ្តាលមកពីការដួល។ ប្រាប់វេជ្ជបណ្ឌិតអ្នកប្រសិនបើអ្នកមានអារម្មណ៍វិលមុខ, ឬមានការផ្លាស់ប្តូរគំហើញឬមានលឺសូរសំលេងនៅក្នុងត្រចៀក។
- ការឈឺចាប់នៅស្មាដែលនៅជាប់មិនបាត់និងរយៈគំលាតនៃលទ្ធភាពក្នុងការធ្វើចលនាមានការថយចុះនៅលើ ដៃដែលថ្នាំបង្ការត្រូវបានចាក់អាចនឹងលេចឡើងបាន ដោយកំរបំផុត បន្ទាប់ពីការផ្តល់ថ្នាំបង្ការ។
- ប្រតិកម្មអាលែកហ្ស៊ីធ្ងន់ធ្ងរពីថ្នាំបង្ការគឺកំរកើតមានណាស់ ត្រូវបានគេប៉ាន់ស្មានមកថាតិចជាង 1ក្នុងចំណោមថ្នាំបង្ការចំនួន 1 លាន។ ប្រសិនបើប្រតិកម្មមួយនឹងកើតមានឡើង, តាមធម្មតាវា នឹងកើតឡើងក្នុងកំឡុងពេលតែប៉ុន្មាននាទីរហូតដល់ប៉ុន្មានម៉ោងប៉ុណ្ណោះបន្ទាប់ពីការផ្តល់ថ្នាំបង្ការ។

សុវត្ថិភាពរបស់ថ្នាំបង្ការគឺកំពុងត្រូវបានត្រួតពិនិត្យតាមដានជាប់ជានិច្ច។ សំរាប់ព័ត៌មានបន្ថែម សូម ចូលទៅកាន់គេហទំព័រ **www.cdc.gov/vaccinesafety/**

## 5 ចុះបើមានប្រតិកម្មធ្ងន់ធ្ងរវិញ?

**តើខ្ញុំគួរស្វែងរកអ្វី?**

- ស្វែងរកនូវអ្វីដែលធ្វើឲ្យអ្នកមានការបារម្ភ ដូចជាសញ្ញានៃប្រតិកម្មអាលែកហ្ស៊ីធ្ងន់ធ្ងរ គ្រុនក្តៅ ខ្ពស់យ៉ាងខ្លាំង ឬបំលាស់ប្តូរអាកប្បកិរិយា។ សញ្ញានៃប្រតិកម្មអាលែកហ្ស៊ីធ្ងន់ធ្ងរអាចរួមមាន ការឡើងហើមកន្ទួលស្បែក ហើមមុខនិងបំពង់ក ពិបាកដកដង្ហើម ចង្វាក់បេះដូងញាប់ វិលមុខ និងខ្សោយកំលាំង។ ចំនុចទាំងអស់នេះគួរតែចាប់ផ្តើមមានឡើងតែប៉ុន្មាននាទីរហូតដល់ប៉ុន្មានម៉ោងប៉ុណ្ណោះបន្ទាប់ពីការ ផ្តល់ថ្នាំបង្ការរួច។

**តើខ្ញុំគួរធ្វើអ្វីខ្លះ?**

- ប្រសិនបើអ្នកគិតថាវាជាប្រតិកម្មអាលែកហ្ស៊ីធ្ងន់ធ្ងរឬស្ថានភាពបន្ទាន់ដទៃទៀតដែលអ្នកមិន អាចពន្យារពេលរង់ចាំបាន, សូមទូរស័ព្ទទៅកាន់លេខ 9-1-1 ឬយកមនុស្សនោះទៅកាន់មន្ទីរពេទ្យនៅជិតបំផុត។ មិនដូច្នោះទេ សូមទូរស័ព្ទរកវេជ្ជបណ្ឌិតរបស់អ្នក។
- បន្ទាប់មក ប្រតិកម្មនោះគួរតែរាយការណ៍ជូនទៅ "ប្រព័ន្ធរាយការណ៍ពីហេតុភេទមិនល្អរបស់ ថ្នាំបង្ការ" (VAERS)។ វេជ្ជបណ្ឌិតអ្នកអាចនឹងរក្សាទុកជាឯកសារនូវរបាយការណ៍នេះ ឬអ្នកអាច ធ្វើវាដោយខ្លួនឯងតាមរយៈគេហទំព័រ VAERS: **www.vaers.hhs.gov** ឬដោយទូរស័ព្ទទៅកាន់ លេខ **1-800-822-7967**។

*VAERS គឺសំរាប់តែរាយការណ៍ពីប្រតិកម្មប៉ុណ្ណោះ។ គេមិនផ្តល់នូវដំបូន្មានផ្នែកវេជ្ជសាស្ត្រឡើយ។*

## 6 តើខ្ញុំស្វែងយល់បន្ថែមយ៉ាងដូចម្តេច?

- សាកសួរវេជ្ជបណ្ឌិតរបស់អ្នក។
- ទូរស័ព្ទទៅកាន់នាយកដ្ឋានសុខាភិបាលក្នុងតំបន់ឬប្រចាំរដ្ឋរបស់អ្នក។ 1–888–767–4687
- ទាក់ទងទៅកាន់មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺ (CDC)៖
  - ទូរស័ព្ទទៅកាន់លេខ **1-800-232-4636 (1-800-CDC-INFO)**
  - ចូលទៅកាន់គេហទំព័រសុខភាពអ្នកធ្វើដំណើររបស់មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺ នៅគេហទំព័រ **www.cdc.gov/travel**
  - ចូលទៅកាន់គេហទំព័រ CDC នៅ **www.cdc.gov/japaneseencephalitis/**

---

Vaccine Information Statement
Japanese Encephalitis Vaccine
Cambodian

01/24/2014

DCH-1262CA
AUTH: P.H.S., Act 42, Sect. 2126.

Translation provided by the California Department of Public Health

ដើម្បីអនុញ្ញាតឲ្យអ្នកផ្តល់ការព្យាបាលសុខភាពស្នើសុំនូវពត៌មានអំពីការចាក់ថ្នាំបង្ការរោគពេញលក្ខណត្រឹមត្រូវ, ការពិនិត្យមើលនៃការចាក់ថ្នាំបង្ការរោគ ហើយនិងការតម្រូវដាក់ពេលវេលា សំរាប់ចាក់ថ្នាំបង្ការរោគនៅអនាគត, ពត៌មានអំពីការចាក់បង្ការរោគនឹងផ្ញើទៅមន្ទីរ Michigan Care Improvement Registry ។ បុគ្គលទាំងឡាយមានសិទ្ធិស្នើសុំអោយអ្នកផ្តល់ការព្យាបាលសុខ ភាពមិនអោយបញ្ជូនពត៌មានអំពីការចាក់ថ្នាំ បង្ការរោគនេះទៅឲ្យកន្លែងទុកសំណុំរឿងបាន។